www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

Free Copies

Vol. 13. Issue #293
April 30Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

នយោបាយកម្ពុជាក្នុងខណៈមាន"កូវីត"
សូមអាននៅទំព័រទី ០៣



ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាព
សូមអាននៅទំព័រទី ០៤




រដ្ឋាភិបាលអាមេរិកនៅតែបន្តជួយពលរដ្ឋ
សូមអាននៅទំព័រទី ០៧



ចំនួនអ្នកកើតកូរ៉ូណាតាមបណ្ដារដ្ឋ...
សូមអាននៅទំព័រទី ០៨



# ប្រាក់ជំនួយ Stimullus ថ្មីជិតចេញមកទៀតហើយ





ដោយ ពិន សំខុន

ខ្លះមិនទាន់បានប្រាក់ជំនួយ១២០០ដុល្លាលើកទី១ផង ស្រាប់តែសភាអាមេរិកាំង គេត្រៀមតាក់តែងច្បាប់ផ្ដល់ជំនួយលើកទី២ ដល់ប្រជាពលរដ្ឋគេ ជាថ្មីម្ដងទៀត គឺដំបូងប្រុងនឹងឱ្យ ២000ដុល្លាម្នាក់ ហើយបន្តទៅទៀត គេឱ្យ ១000ដុល្លាក្នុងរយពេល១ឆ្នាំបន្ទាប់ពី"កូវីដ១៩ ឱ្យត្រូវបានបញ្ចប់ ។

**នរណាខ្លះដែលទទួលជំនួយ"ស្ទីមូលុស" ថ្មីនោះ?**

គឺប្រជាពលរដ្ឋទាំងអស់គ្នា នឹងបានទទួលប្រាក់នោះ គេនឹងដាក់បញ្ចូលក្នុង ខត Debit card ម្នាក់មួយជូនពលរដ្ឋទាំងអស់ ដែលជា

១* អ្នកបាន ធ្វើតាក់

២* អ្នកក្រោមអណាព្យាបាល

៣* អ្នកគ្មានគណនេយ្យក្នុងធានាគារ, គ្មានសូសុល សេគុរីទី, ឬគ្មានអស័យដ្ឋានពិតប្រាកដ

៤* អ្នកមិនមានសញ្ជាតិអាមេរិកាំង

៥* អ្នកដែលរស់នៅដែនដី ចំណុះសហរដ្ឋអាមេរិកាំង, ឬក៏ជនអាមេរិកាំងរស់នៅឯបរទេស

"ខត"ទាំងនោះនឹងត្រូវបញ្ជូន ១* តាមប្រៃសនីយ ២* កំណត់កន្លែងឱ្យមកយក ៣* យកទៅឱ្យផ្ទាល់ដៃ ។

ច្បាប់ Cares Act ថ្មីនេះមិនទាន់អនុម័តនៅឡើយទេ តែសមាជិកសភាជាច្រើន មានការពេញចិត្តនឹងសំណើរ ដែលចេញពីព្រឹទ្ធសមាជិក រ៉ាឌីស្លា តាឡិប នឹង ប្រមីឡា ជយ៉ាប៉ាល់ ។



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
*Excellent Service Since 1987*

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តនូវទំនុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបំរើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

Law Office of Louis S. Haskell • 16 Pine Street • Lowell, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# We're OPEN

**Lowell Primary Care Center**
**OPEN DURING COVID-19 PANDEMIC**

## Telehealth

**Primary Care & Behavioral Health**




មណ្ឌលពិនិត្យសុខភាពឡូវែល
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ **COVID-19**
តាមរយៈ **Telehealth**
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត

**Call: (978) 455-7992**

# We're OPEN

**Lynn Primary Care Center**
**OPEN DURING COVID-19 PANDEMIC**

## Telehealth

**Primary Care & Behavioral Health**




មណ្ឌលពិនិត្យសុខភាពលីន
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ **COVID-19**
តាមរយៈ **Telehealth**
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត

**Call: (781) 780-7755**

# ឥណទានផ្ទះ (ការខ្ចីសម្រាប់ទិញផ្ទះ)

✓ កម្មវិធីឥណទានទិញ និងការបង់ឡើងវិញ
✓ កម្មវិធីអ្នកទិញផ្ទះលើកដំបូង
✓ នឹងអាចមានទៅបាននូវកម្មវិធីអត្រាគង់ និងអត្រាផ្លាស់ប្តូរ
✓ ឥណទានអាស្រ័យតាមតម្លៃផ្ទះ
✓ ឥណទានសម្រាប់ការសាងសង់ទៅជាការខ្ចីរហូត៍



មជ្ឈមណ្ឌលនិក្ខេប
នៅធនាគារអេនធ័រប្រៃស៍

978-656-5653 | 877-671-2265

ដាក់ពាក្យតាមអិនធឺណិតនៅ EnterpriseBanking.com/Mortgage

EnterpriseBanking.com/Mortgage

Member FDIC

Enterprise Bank
CREATE SUCCESS

# នយោបាយកម្ពុជាក្នុងខណៈមាន“កូវិដ ១៩”

ដោយ ពិន សំខុន

ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រឿងជាច្រើន បានបង្កកើតជាវិបត្តិយ៉ាងឈឺចាប់ ដល់ប្រជាពលរដ្ឋខ្មែរ បន្ថែមពីលើឧប្បត្តិហេតុ“កូវិដ១៩”ដែលធ្ងន់ធ្ងរណាស់ទៅហើយ ។ ប៉ុន្តែលោក ហ៊ុន សែន មិនបានបញ្ឈប់នយោបាយលើផ្លូវខុសនេះទេ បែរជាជាន់បន្ថែមល្បឿនទម្លាក់ជ្រោះជ្រៅទៀត ។ ដែលបាន“ផ្ទុះមេរោគកូរ៉ូណា”នៅក្នុងទីក្រុងវូហាន របស់ខ្លួន...។

ប្រទេសចិន បានប្រឹងលាក់អាថិកំបាំងពត៌មានស្តីពី“កូរ៉ូណា១៩”ផ្ទុះនៅទីក្រុង“វូហាន”ជាមួយលោក ហ៊ុន សែន ពីខែធ្នូ២០១៩ រហូតដល់ខែកុម្ភៈ ២០២០ ទើបដំណឹងផុសឡើង... តែយឺតពេលបន្តិចទៅហើយ! ពីព្រោះប្រទេសកូរ៉េខាងត្បូង ប្រទេសអ៊ីតាលី បានផ្ទុះឆ្លងជម្ងឺដោយសហរដ្ឋអាមេរិកក្តី ដោយសមមិត្រវៀតណាមកុម្មុយនិស្តដូចគ្នាក្តី... ស្របគ្នានឹងសត្រូវផ្ទៃក្នុងឈ្មោះ “កូវិដ១៩” ចិនក៏តម្រូវបន្ទន់ខ្លួនប្រមូលប្រជាជនខ្លួន ទាហ៊ានខ្លួន ចេញពីស្រុកខ្មែរត្រឡប់ទៅស្រុកខ្លួនវិញ, បណ្តាលឱ្យស្ថានភាពសេដ្ឋកិច្ចខ្មែរសេដ្ឋកិច្ចគ្រួសារលោកសេដ្ឋី ហ៊ុន សែន ដាំក្បាលចុះយ៉ាងអណោចអធម្ម,... ហេតុនេះហើយ បានជាលោក ហ៊ុន សែន នៅប៉ែកាំងតាំងពីផ្តើមកូវិដ១៩មកម្ល៉េះ ។ ព្រះអង្គមិនដែលបានទុកព្រះទ័យលើកិច្ចការពារទ្រង់ដោយរដ្ឋបាលលោក ហ៊ុន សែន ទេ, ហេតុនេះហើយបានជា“ការប្រកាសភាពអាសន្នរបស់ខ្មែរ” ដោយដំណាងព្រះមហាក្សត្រ គឺលោក សាយ ឈុំ ប្រធានព្រឹទ្ធសភា ក៏បានក្លាយជា“រដ្ឋប្រហារសម្រាប់ភ្នែកវៀតណាម”។ លោក ហ៊ុន សែន ក៏បានដឹងថា“អំណាចស្របច្បាប់” បានរបូតពីដៃរបស់លោកទៅហើយដែរ ។

អំណាចយោធានឹងប៉ូលិស នាពេលប្រកាសភាពអាសន្ន បើយោងតាមរដ្ឋធម្មនុញ្ញខ្មែរ ត្រូវស្ថិតនៅក្រោមបញ្ជាព្រះមហាក្សត្រ ដែលនៅប៉េកាំង ព្រះអង្គមានកងទ័ពនឹងកងប៉ូលិស រួចជាស្រេច ហើយដែលអាចវាយផ្តាច់យកកម្ពុជាក្រោម នាពេលនេះបាន,... នេះក៏ ព្រោះតែ ព្រះអង្គជាមិត្តពិតប្រាកដ, ដ៏ស្មោះត្រង់នឹងជាអំណាចស្របច្បាប់របស់ចិន ពុំមែន ហ៊ុន សែន ឬ សាយ ឈុំ នោះទេ។



ព្រះមហាក្សត្រនរោត្តម សីហមុនី



សម្តេច ហ៊ុន សែន



សម្តេច សាយ ឈុំ



លោក កឹម សុខា





កងទ័ពវៀតណាមមកបោះតង់នៅព្រំប្រទល់ដែនខ្មែរវៀតណាម ត្រូវប៉ូលិសខ្មែរបណ្តេញចេញ

**តើហេតុអ្វីបានជាលោក ហ៊ុន សែន ប្រថុយគ្រោះថ្នាក់ ?**

លោក ហ៊ុន សែន បានបោះបង់លក្ខខណ្ឌគោរពសិទ្ធិមនុស្សរបស់ EBA សហភាពអឺរ៉ុបនៅខែមិនា២០១៩ដើម្បីចាប់យកចំណងមេត្រីភាពជាមួយប្រទេសចិន ដែលកំពុងតែវាទទឹកដីនៅអាស៊ីអគ្នេយ៍, អាស៊ី កណ្តាល, អាស៊ីខាងកើត នឹង អាហ្វ្រិក រហូតដល់អឺរ៉ុបទៀតផង... ផ្លូវសូត្ររបស់ចិនបានលូនទៅគ្រប់តំបន់ទន់ខ្សោយសេដ្ឋកិច្ចនៃពិភពលោក ពីព្រោះចិននឹងក្លាយទៅជាមហាអំណាចពិភពលោកបាន បើចិនទប់ស្កាត់ការគម្រាមកំហែងរបស់សហរដ្ឋអាមេរិកបានពិតមែននោះ ។

ការទៅធ្វើទស្សនកិច្ចរបស់លោក ហ៊ុន សែន នៅប្រទេសចិន ដើម្បីបង្ហាញ នាខែមករា ២០២០ ថា“គូរ៉ូណាវ៉ាយរ៉ុស”ដែលបើ្តមរាតត្បាតចេញពីប្រទេសចិន ពុំមានអ្វីធ្ងន់ធ្ងរនោះទេ...ដែលនោះគឺជាការ“ផ្គាប់ចិត្ត” ជាពិសេសដល់ប្រទេសចិន “កូវីដ១៩”នេះ យ៉ាងធ្ងន់បាត់ទៅហើយ...។

លោក ហ៊ុន សែន បានអនុវត្តន៏នយោបាយ “ដើរលើខ្សែតឹងលាតសន្ធឹងទៅរកប្រទេសចិន” ដែលលោករំពឹង ដូចសម្តេច សីហនុ កាលពីឆ្នាំ ១៩៦០ ថា “ប្រថុយជួយចិនពេលនេះ ចិនមុខតែនឹងឈ្នះនៅតំបន់អាស៊ី ប៉ាស៊ីហ្វិកនេះ” ពេលនោះលោកនឹងបានក្លាយទៅជា“អាគាំងចៅតា” ដ៏ជិតស្និតនឹងជាអ្នកធំរបស់ “ព្រះឥន្ទ្រាធិរាជចិន” ម្តងវិញ... ហើយលាភសក្ការៈនឹងហូរចូលក្រុមគ្រួសារលោក ដូចដែលយើងបានឃើញ នា២,៣ ឆ្នាំចុងក្រោយនេះមែន... ក៏ប៉ុន្តែការប្រថុយប្រថាននោះ គឺបានដាក់ជីវិតរបស់ប្រជាពលរដ្ឋខ្មែរដាក់ទឹកដីប្រទេសខ្មែរ ព្រមទាំងគណបក្សប្រជាជនខ្លួនឯងក៏សុខចិត្តលក់ដែរ ដោយពុំមានសួរយោបល់នរណាម្នាក់ណាឡើយ...។

លទ្ធផលដែលទទួលបានគឺៈ

នៅពេលដែលព្រះឥន្ទ្រាធិរាជចិនកុម្មុយនិស្តមិនបានត្រូវខ្លបខ្លាចដោយសហភាពអឺរ៉ុបក្តី តែឱបជើងប្រទេសចិនអង្វរករកុំឱ្យចាកចេញពីកម្ពុជាទៅវិញអី, ទីក្រុងទេសចរខ្មែរ ចំណាត់ថ្នាក់ពិភពលោកបានក្លាយជារហោដ្ឋាន, រោងចក្រជាច្រើន បានបិទទ្វារ, ការសន្យារបស់ ហ៊ុន សែន ថា ជួយចេញប្រាក់ខែឱ្យកម្មករ ក៏បានក្លាយជាពាក្យភូតភរ...។

ចិននៅកម្ពុជាខាតបង់វិនិយោគវាល់កោដិមែន តែគេបានយកកម្ពុជាជា “ជម្រកយោធា” បានរួចទៅហើយ ដែលនេះជាការគម្រាមដល់ការកាន់កាប់ដីថ្មីយកពីខ្មែរនឹងសន្តិភាពដ៏ផុយស្រួយរបស់វៀតណាម ។

ស្រាប់តែចុងខែមេសា ២០២០ នៅពេលសភាខ្មែរបោះឆ្នោត“ប្រកាសភាពអាសន្ន”ដើម្បីទប់ស្កាត់កូវិដ១៩សោះនោះ ស្រាប់តែវៀតណាមបែរជាវាយទ័ពតាមព្រំដែនខ្មែរ...។

**ហេតុអ្វីក៏ទ័ពវៀតណាមវង្វេងផ្លូវទៅវិញ ?**

កត្តាព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហមុនី បានយាងចេញពីកម្ពុជាទៅប្រថាប់

**សម័យ“កូវិដ១៩”ជាសង្គ្រាមរួម**

ដោយសារអវត្តមាននៃគណបក្សប្រឆាំងស្របច្បាប់គ្មាននរណាជឿពីស្ថានភាពពិតរបស់កម្ពុជានោះទេ។ ប៉ុន្តែភាពរងគ្រោះ, គ្រោះថ្នាក់, ចលាចល, មិនហ្នឹងហ្ន របស់កម្ពុជា នាពេលនេះ បានត្រូវមន្ត្រីរាជការគ្រប់ក្រុង ខេត្ត ខណ្ឌ, បានកាត់ប្រាក់ខែ ៦ខែម្នាក់ យ៉ាងស្រុសគ្នា ចូលរួមដោយអ្នកជំនួញ រួមទាំងឯកជនរាប់ម៉ឺននាក់ បានធ្វើអំណោយជំនួយសង្គ្រោះ តាមរយៈចលនា “កូវិដ១៩” បានប្រាក់រាប់រយលាន...ក្នុងនោះក៏មានឈ្មោះលោក កឹម សុខា ជាប្រធានគណបក្សសង្គ្រោះជាតិបានធ្វើអំណោយចំនួនប្រាក់ ៥ពាន់ដុល្លារ ដល់ចលនា “កូវិត១៩”ក្នុងលំដាប់លេខរៀង២៩៤ នឹងគេដែរ។

ពេលនេះ យើងពុំទាន់ឃើញសេចក្តីរាយការណ៏ចេញពីក្រសួងស្តីពីវាសនានៃជំនួយនោះមកវិញនៅឡើយទេ។

# “ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន” ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ហើយ

ភ្នំពេញ : ទីបំផុតទៅ “ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន” ដែលជាច្បាប់ថ្មីសន្លាងនៅក្នុងប្រទេសកម្ពុជា ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការហើយ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០នេះ។

ច្បាប់ស្តីពី “ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន” ត្រូវបានចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់ដោយប្រមុខរដ្ឋស្តីទីសម្តេចវិបុលសេនាភក្តី សាយ ឈុំ។

រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន កាលពីខែមេសា ឆ្នាំ២០២០-កន្លងទៅនេះ បានចាប់ផ្តើមរៀបចំ និងតាក់តែងឡើងនូវច្បាប់ស្តីពី “ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន” ចំពេលប្រទេសកម្ពុជារងការរាតត្បាតនៃជំងឺកូវីដ១៩។ ច្បាប់នេះត្រូវបានរៀបចំឡើងក្នុងល្បឿនមួយយ៉ាងលឿន ហើយត្រូវបានរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញអនុម័តជាបន្តបន្ទាប់ត្រឹមរយៈពេលតែមួយខែប៉ុណ្ណោះ។

សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ធ្លាប់បានគូសបញ្ជាក់ថា ច្បាប់នេះគឺជាឧបករណ៍ផ្នែកច្បាប់ដ៏មានសារៈសំខាន់សម្រាប់កម្ពុជា ក្នុងការគ្រប់គ្រងប្រទេសនៅពេលមានគ្រោះអាសន្នផ្សេងៗ ខណៈបច្ចុប្បន្នកម្ពុជាមិនទាន់មានច្បាប់សម្រាប់ការគ្រប់គ្រងប្រទេសពេលមានអាសន្ននៅឡើយ។




រាជរដ្ឋាភិបាលកម្ពុជា ធ្លាប់បានអះអាងថា ច្បាប់ស្តីពីការគ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវបានរៀបចំឡើងដោយផ្អែកតាមស្មារតីនៃមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា ដែលចែងថា “នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រីប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា”។

ច្បាប់ថ្មីនេះ ក៏ផ្តល់ជាមូលដ្ឋានគតិយុត្ត ដើម្បីធានាដល់ការអនុវត្តមាត្រា២២ថ្មីនៃរដ្ឋធម្មនុញ្ញ និងជាមូលដ្ឋានគតិយុត្តកំណត់សិទ្ធិអំណាចរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវវិធានការចាំបាច់ដែលមិនអាចខ្វះបាន ដើម្បីឆ្លើយតបទៅនឹងស្ថានភាពរបស់ប្រទេសក្នុងភាពអាសន្ន សំដៅការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈការពារអាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពាំរទ្រព្យសម្បត្តិ និងបរិស្ថាន។

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក៏កំណត់នូវបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រមទាំងវិធានការចាំបាច់នានាដែលរាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នបានបញ្ជាក់ថា ការដាក់ប្រទេសជាតិក្នុងភាពអាសន្នអាចធ្វើឡើងនៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ជាអាទិ៍,គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស, គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ, ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ

តទៅទំព័រទី ០៥





មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មុី សុខារិទ្ធ, **M.D.**

**Sokharith Mey, M.D.**

លោក ឆាន់ ទូច , **C.N.P.**

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine***

&

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# រដ្ឋាភិបាលអាមេរិកនៅតែបន្តជួយពលរដ្ឋនឹងអ្នកជំនួញ

ដោយ ពិន សំខុន

## លុយជំនួយលើកទី១

ថវិការជំនួយនេះ បានផ្តល់ទៅដល់ប្រជាពលរដ្ឋតែងពីពាក់កណ្តាលខែមេសា ជាបន្តបន្ទាប់។ អ្នកដែលធ្លាប់បានធ្វើតាក់ឆ្នាំ២០១៨, ១៩ ឬក៏ទទួលប្រាក់សោធន៏និវត្តន៏ ឬក៏ប្រាក់ពិការជាស្វ័យប្រវត្តិក៏បានឃើញលុយ១២00 ដុល្លា,ម្នាក់ចូលគណនេយ្យធានាគាររួចហើយដែរ។

រីឯអ្នកដែលធ្វើតាក់យឺតពេល ឬក៏ ទើបនឹងបាន "គ្រីនខត" ពីឆ្នាំមុន ឬក៏សិស្សានុសិស្ស "VisaH1B" ក៏ត្រូវតែរង់ចាំលុយនៅសប្តាហ៍បន្តបន្ទាប់យ៉ាងតក់ក្រហល់ ពីព្រោះតែរដ្ឋាភិបាលអាមេរិកាំងមិនដែលឱ្យលុយចាយទទេៗ ដូចពេលនេះទេ។

ចំណែកអ្នកដែលបាត់បង់ការងារធ្វើ ឬក៏កំពុងតែខិតខំទៅធ្វើការ(ខ្លាចគេដេញចោល) មិនបានដឹងទេថា រដ្ឋបាលលោកប្រធានាធិបតី ត្រាំ "ខ្លាចការរាលដាលជម្ងឺច្រើនជាងអ្នកគ្មានការងារធ្វើនោះទេ" ម្លោះហើយក៏នៅតែសង្ស័យប្រថុយទៅប្រកបការងារទាំងគ្រោះថ្នាក់ដល់ជីវិតតទៅទៀត។ ចំណែកអ្នកដែលមិនប្រថុយទៅធ្វើការវិញ គេបើកប្រាក់គ្មានការងារធ្វើនូវ Employment ប្រាក់ដោយហាងខ្លួនបិទទ្វារប្រាក់ដោយមានអ្នកឆ្លងជម្ងឺនៅក្បែរខ្លួន... អាចបានច្រើនជាងប្រាក់ដែលខ្លួនកំពុងធ្វើការថែមទៀតផង។



បើងាកទៅមើលអ្នករកស៊ីវិញ បែបពិបាកមើលបន្តិច! ពីព្រោះរដ្ឋបាលលោកប្រធានាធិបតី ត្រាំ បានយកលុយទៅជួយសហគ្រាសធំៗ មុនគេ រហូតដល់អស់លុយទី១ មិនអាចជួយទៅដល់សហគ្រិនតូចៗទេ។ ដូច្នេះហើយ បានជា "ប៊ីសនីស" តូចៗប្រមាណ៧0ម៉ឺនហាង មិនបានទទួលជំនួយកម្ចីអ្វី ដូចដែលបានសន្យា កាលពីសប្តាហ៍មុននៅឡើយទេ។ សភាបានឱ្យលុយថ្មី៤៥0ប៊ីល្យុងទៀត ដល់លោក ត្រាំ ដើម្បីបនជួយអ្នករកស៊ីតូចៗ តាមលំដាប់លំដោយនៃអ្នកដាក់ពាក្យសុំមុនគេ។

អ្នករកស៊ី "ប៊ីសនីស" តូចធំខ្មែរ ដែលមានបុគ្គលិកធ្វើការ Employer ដូចជាហាងលក់ដូរទំនិញ, ហាងលក់បន្លែបង្កា ត្រីសាច់, ភោជនីយដ្ឋាន,...នឹង "ប៊ីសនីស" ដែលធ្វើការតែម្នាក់ឯង Self employ មានអ្នកបើកបររថយន្ត, អ្នកកាត់សក់ អ៊ុតសក់, អ្នកធ្វើក្រចក, ជាងម៉ៅការសំណង់,.... សុទ្ធតែនៅក្នុងគោលដៅនៃជំនួយពីរដ្ឋាភិបាលទាំងអស់ តែត្រូវដាក់ពាក្យសុំជាមុនដើម្បីឱ្យបានជុំនួយនោះ សម្រាប់ទ្រទ្រង់កុំឱ្យហាងដួលរលំ។ អ្នកដែលសុំមិនទាន់ពេលថវិការដែលត្រៀមមុខតែនឹងស្រកចុះយ៉ាងលឿនហើយខ្វះអ្នកមកដល់ក្រោយគេជាមិនខាន។

សូមរំលឹកឡើងវិញ នូវជំនួយដែលយើងបានជម្រាបជូន កាលពីលេខមុន គឺៈ

១-កម្ចីជាប្រាក់ ១ម៉ឺនដុល្លា មិនចាំ បាច់សង ដើម្បីធានាដំណើរការបច្ចុប្បន្នរបស់ "ប៊ីសនីស"

២-កម្ចីរហូតដល់២លាន ដោយការប្រាក់ទាប(0,5 %) ហើយដែលសំណងទៅធនាគារវិញអាចចាប់ផ្តើមនៅ២ឆ្នាំក្រោយ សម្រាប់ត្រៀមបន្តសកម្មភាពជំនួញ ពេល "គូវីដ១៩" ចប់។

សភាបានបោះឆ្នោតបញ្ចេញថវិការថ្មីជាង៤ពាក់លានទៀត សម្រាប់បន្តជំនួយទប់ស្កាត់កូវីដ១៩

### ស្ថានភាពរាលដាលរបស់ "កូវីដ១៩"

ថ្វីត្បិតតែលោកប្រធានាធិបតី ឌុណល ត្រាំ ប្រកាសថា "កូវីដ១៩" នៅពីក្រោយយើង "ហើយក៏ដោយក្តីចំនួនអ្នកឆ្លងជម្ងឺថ្មីនៅតែកើនឡើងយ៉ាងច្រើនដដដែល។ ទំនងជាឱកាសដែលមានជនឆ្លងជម្ងឺ ហើយស្លាប់ច្រើនជាងគេ បានកន្លងហួស នាចន្លោះថ្ងៃទី១៤, ទៅ២0មេសា រងគ្រោះហើយថា តទៅទំព័រទី 0៩



# ចំនួនអ្នកកើតកូវូណាតាមបណ្តារដ្ឋក្នុងសហរដ្ឋអាមេរិក

ចំនួនករណីនៃជំងឺកូវីត-១៩ នៅតែបន្តកើនឡើងក្នុងសហរដ្ឋអាមេរិក។ រហូតមកដល់ពេលនេះអ្នកជំងឺ ៨០% ដែលមានរោគសញ្ញាស្រាលដូចជាគ្រុនក្តៅ និងរលាកសួត ហើយភាគច្រើន



អ្នកជំងឺទាំងនេះគឺតម្រូវអោយមានការព្យាបាលដោយប្រើប្រាស់ថ្នាំពេទ្យតិចតួចបំផុត តែសម្រាប់មនុស្សចាស់ និងអ្នកដែលមានជម្ងឺដូចជា ទឹកនោមផ្អែម ឬបញ្ហាបេះដូង និងសួតគឺងាយរងគ្រោះបំផុត។ អត្រានៃការស្លាប់របស់ប្រទេសចិនដោយសារមេរោគកូវូណាភាគច្រើន គឺអ្នកដែលមានអាយុ៨០ឆ្នាំឡើងមានករណីជាង៧២,០០០ករណីគឺស្មើនឹង១៤,៨%បើតាមការសិក្សារបស់រដ្ឋាភិបាលអាមេរិក។

ករណីនៃជំងឺកូវីត-១៩នៅសហរដ្ឋអាមេរិចមានច្រើនបំផុតនៅក្រុងញូយ៉កមានប្រហែល៣០ម៉ឺននាក់។ ញ៉ូ ជេស៊ី ឈរលំដាប់ទី ២ បន្ទាប់ពីញូយ៉ក ដែលមានចំនួននាក់កើតជាង ១០ ម៉ឺននាក់ ហើយរដ្ឋម៉ាសាជូសេតនៅលំដាប់ទី៣ មានចំនួនអ្នកកើតជាង ៦ ម៉ឺននាក់។ ខាងក្រោមនេះគឺជាតារាងចំនួនអ្នកកើតជំងឺកូវូណាតាមរដ្ឋនីមួយៗពីច្រើនមកតិច ហើយជាព័ត៌មានចុងក្រោយបង្អស់នៅថ្ងៃទី១ ខែឧសភា។

| State/territory | Confirmed cases | Deaths |
|---|---|---|
| Massachusetts | 62,205 | 3,562 |
| Illinois | 52,918 | 2,355 |
| California | 50,411 | 2,046 |
| Pennsylvania | 48,134 | 2,475 |
| Michigan | 41,379 | 3,789 |
| Florida | 33,690 | 1,268 |
| Texas | 28,728 | 812 |
| Louisiana | 28,001 | 1,905 |
| Connecticut | 27,700 | 2,257 |
| Georgia | 26,940 | 1,138 |
| Maryland | 21,742 | 1,140 |
| Ohio | 18,027 | 976 |
| Indiana | 17,835 | 1,114 |
| Virginia | 15,847 | 552 |
| Colorado | 15,284 | 777 |
| Washington | 14,327 | 814 |
| North Carolina | 10,754 | 406 |
| Tennessee | 10,735 | 199 |
| Rhode Island | 8,621 | 266 |

តទៅទំព័រទី ០៩



តមកពីទំព័រទី ០៨
## ចំនួនអ្នកកើតកូរ៉ូណា...

| | | |
|---|---|---|
| Missouri | 7,825 | 351 |
| Arizona | 7,655 | 320 |
| Iowa | 7,145 | 162 |
| Alabama | 7,088 | 272 |
| Wisconsin | 6,854 | 316 |
| Mississippi | 6,815 | 261 |
| South Carolina | 6,095 | 244 |
| Minnesota | 5,136 | 343 |
| Nevada | 5,054 | 243 |
| Delaware | 4,734 | 152 |
| Kentucky | 4,708 | 240 |
| Utah | 4,672 | 46 |
| Kansas | 4,413 | 134 |
| District of Columbia | 4,323 | 224 |
| Nebraska | 4,281 | 70 |
| Oklahoma | 3,618 | 222 |
| New Mexico | 3,411 | 123 |
| Arkansas | 3,281 | 61 |
| Oregon | 2,510 | 103 |
| South Dakota | 2,449 | 17 |
| New Hampshire | 2,146 | 72 |
| Idaho | 2,015 | 63 |
| Puerto Rico | 1,575 | 94 |
| West Virginia | 1,125 | 41 |
| Maine | 1,095 | 53 |
| North Dakota | 1,067 | 19 |
| Vermont | 866 | 49 |
| Hawaii | 618 | 16 |
| Wyoming | 559 | 7 |
| Montana | 453 | 16 |
| Alaska | 355 | 9 |
| Guam | 145 | 5 |
| Virgin Islands | 66 | 4 |

# សមាគម"អាសេឡិច"មានអ្នកជួយធ្វើ សំណុំរឿងជួយដល់អ្នកការធ្វើ

-ពាណិជ្ជករចង់បានប្រាក់ជំនួយជាប្រាក់កម្ចីរបស់រដ្ឋ និងជួយដល់អ្នកដែលមិនបានទទួល ស៊ីមេលីស

សូមទូរស័ព្ទមកសមាគម "អាសេឡិច" ទូរស័ព្ទលេខ 978-942-8490

តមកពីទំព័រទី ០៧
## រដ្ឋាភិបាលអាមេរិកនៅតែបន្តជួយ ពលរដ្ឋនិងអ្នកជំនួញ...

គ្រោះកំណាចនៅពីក្រោយយើងទៅ ហើយនោះ ទំនងជាមិនប្រាកដនិយមនៅឡើយទេ។ លោកប្រធានាធិបតី ត្រាំ មានបំណងបើកសហរដ្ឋឱ្យដំណើរការវិញនៅថ្ងៃទី១១ ខែឧសភា បានត្រូវអ្នកឯកទេសមួយចំនួនជំទាស់ថា ប្រទេសអាចនឹងទទួលរងគ្រោះយ៉ាងធ្ងន់ម្តងទៀត ។

គ្រាន់តែនៅឡូវែលរដ្ឋម៉ាសាឈូសិត ដ៏សម្បូរប្រជាជនខ្មែររស់នៅ នាឆ្នេរខាងកើតមានមនុស្សឆ្លងជម្ងឺ "កូវីដ១៩" មិនដល់១ខែផង ចំនួន១៥៦៨នាក់ទៅហើយ ហើយចំនួនអ្នកស្លាប់ដល់ទៅ៤៨នាក់។ សូមពិនិត្យតារាងភ្ជាប់ជាមួយនេះ សម្រាប់តំបន់ដែលលោកអ្នករស់នៅ...។


DAN O'BRIEN | DAN O'BRIEN

សូមស្វាគមន៍ និងសូមមកកាន់ភ្នាក់ងារលក់ ដើម្បីទិញរថយន្តថ្មីរបស់អ្នកនៅថ្ងៃនេះ! យើងមានការបញ្ចុះតម្លៃរាប់រយគ្រឿងនៃរថយន្តថ្មី និងរថយន្តប្រើប្រាស់រួចៗ ដូចជា sedans, jeeps, និង mini vans នៅក្នុងស្តុករបស់យើងៗ ទស្សនាទីតាំងរបស់យើងដែលនៅជិតអ្នកបំផុត ឬទូរស័ព្ទ វុទ្ធី យក់ សសម្រាប់រត់ជួប



Vuthy Yok វុទ្ធី យក់
Sales and Leasing Consultant
Office (978) 746-2500 Ext. 58316
Cell (978) 621-3842
vyok@danobrienautogroup.com




- One Year Maintenance Included
- One Year Paintless Dent Repair
- Free Safety Inspections for you and your entire household
- Lifetime Power-train Warranty

DAN O'BRIEN NISSAN
95 DRUM HILL ROAD,
CHELMSFORD, MA 01824
http://www.DanOBrienNissan.com

DAN O'BRIEN CDJR
175 PELHAM ST,
METHUEN, MA 01844
https://www.danobriencdjr.com



KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក





អគ្គនាយក សុបិន្ទ ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com





និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com





Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng



The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA





# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រីការមើលការខុសត្រូវក្នុងកំឡុង ពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្អកស្នាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺឱ្យមានអ្នកមកមើលថែអ្នកដែលជា ស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយវ៉ឺស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការទាក់ទងនឹងមនុស្សឯទៀត, រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នក ដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប, ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្វាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌល់ថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នកមិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជុំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរាបង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទួលរង់ចាំក្នុងការទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្រ្ត។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ និងនំចំណីបំប៉នច្រើន
- ថ្នាក់កីឡារជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពយ៉ាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា DADC**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពីនទិស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលច

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ជាឯកជន
- ទទួលយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស, ស្ពេននីស, ខ្មែរ, ឡាវ, ម៉ោង, ប៉័ទុយគ្កាល់, សូវៀត និងតាហ្កាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹង ផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រង មេឌីឃេត សម្រាប់សេវាថាទាំចាស់ជរាលោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។

# រូបមន្តធម្មជាតិទាំងនេះ អាចកម្ចាត់មុន ក្បាលខ្មៅយ៉ាងមានប្រសិទ្ធភាព



**ឡើងមុនក្បាលខ្មៅ និងក្បាលសជាបញ្ហាទូទៅបំផុតមួយដែលកើតមានមិនថា ចំពោះមនុស្សប្រុស ឬស្រី! ភាគច្រើនវាកើតមានត្រង់ចង្កា និងច្រមុះ។ ទោះជាយ៉ាងណាកុំបារម្ភ! ខាងក្រោមនេះជារូបមន្តធម្មជាតិងាយៗដែលអាចជួយដោះស្រាយបញ្ហាស្បែកងាប់ៗនិងកម្ចាត់មុនក្បាលខ្មៅនិងក្បាលសឆាប់រហ័ស :**

**១. ផ្នែកពណ៌សនៃស៊ុត**

ជាប្រភពដ៏ប្រសើរនៃសារធាតុសេលេញ៉ូមដែលមានលក្ខណៈសម្បត្តិប្រឆាំងការរលាក កម្ចាត់មុនបានយ៉ាងឆាប់រហ័ស។ ជាដំបូងអ្វីដែលអ្នកត្រូវធ្វើ គឺលាងសម្អាតមុខឱ្យស្អាត និងជូតផ្តិតឱ្យស្ងួតជាមុនសិន។ បន្ទាប់មកកូរវីកផ្នែកពណ៌សនៃស៊ុតរួចលាបពី ៣ ទៅ ៥ ស្រទាប់លើស្បែកមុខដែលមានបញ្ហាមុន។ ទោះជាយ៉ាងណាត្រូវទុកឱ្យស្រទាប់នីមួយៗស្ងួតសិនសឹមលាបមួយស្រទាប់ៗបន្ត។ នៅពេលមានអារម្មណ៍ថាតឹងស្បែកឬម៉ាសស្ងួត ចូរបកថ្នមៗ និងលាងសម្អាតមុខចេញជាការស្រេច។ អ្នកក៏អាចលាយផ្នែកពណ៌សនៃស៊ុត ១ គ្រាប់ ជាមួយទឹកក្រូចឆ្មារ កន្លះស្លាបព្រាកាហ្វេ និងទឹកឃ្មុំ ចំនួន ១ស្លាបព្រាកាហ្វេ។ កូរលាយចូលគ្នាឱ្យសព្វសឹមលាបល្បាយលើតំបន់ស្បែកដែលទទួលរងផលប៉ះពាល់ដោយសារមុនក្បាលខ្មៅ។ ទុកចោលសម្រាប់រយៈពេល១៥នាទី ហើយលាងសម្អាតចេញជាមួយទឹកក្តៅឧណ្ហៗជាមុនសិន សឹមលាងជាមួយទឹកត្រជាក់តាមក្រោយ។

២. ទឹកឃ្មុំលាយទឹកដោះគោស្រស់

អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាយទឹកឃ្មុំ ១ ស្លាបព្រាបាយជាមួយទឹកដោះគោស្រស់ ១ស្លាបព្រាបាយ។ កូរឱ្យសព្វសឹមលាបល្បាយមួយជាន់លើមុនក្បាលខ្មៅ។ បន្ទាប់មកប្រើប្រាស់ក្រដាសជូតមាត់សង្កត់ពីលើ។ ទុកឱ្យស្ងួតសម្រាប់រយៈពេលប្រហែល ២០នាទី។ សឹមបកចេញថ្នមៗនិងលាងសម្អាតចេញជាមួយទឹកត្រជាក់។

៣. ទឹកក្រូចឆ្មារស្រស់

លាងសម្អាតមុខឱ្យស្អាត រួចជូតឱ្យស្ងួត។ បន្ទាប់មកប្រើប្រាស់ដុំសំឡីជ្រលក់ទឹកក្រូចឆ្មារស្រស់លាបលើតំបន់ស្បែកដែលទទួលរងផលប៉ះពាល់។ អនុវត្តឱ្យបានពី ២ ទៅ ៣ ដងក្នុងមួយសប្តាហ៍មុនពេលចូលគេង។ លាងសម្អាតចេញនៅពេលព្រឹក។

៤. ប្រទាលកន្ទុយក្រពើ

លាយសាច់ ឬជែលប្រទាលកន្ទុយក្រពើចំនួន ១ ស្លាបព្រាបាយជាមួយទឹកក្រូចឆ្មារស្រស់ចំនួនពី២ទៅ៣ដំណក់។ កូរឱ្យសព្វ សឹមលាបទឹកល្បាយលើមុន ឬតំបន់ស្បែកដែលទទួលរងផលប៉ះពាល់។ ទុកចោលរហូតដល់ស្បែកស្រូបយកជាតិល្បាយ។ ហើយដើម្បីកម្ចាត់ក្បាលខ្មៅអ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាបជែលប្រទាលកន្ទុយក្រពើស្រស់លើមុនក្បាលខ្មៅ និងទុកចោលសម្រាប់រយៈពេលប្រហែល ១០ នាទី សឹមលាងសម្អាតចេញជាមួយទឹកក្តៅឧណ្ហៗជាការស្រេច។ អនុវត្តរាល់ថ្ងៃជាប្រចាំដើម្បីទទួលបានស្បែកស្រស់ថ្លារលោងស្អាត។

៥. ទឹកខ្ទុរមាត់

អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាបទឹកខ្ទុរមាត់លើមុនក្បាលខ្មៅទាំងនោះជាការស្រេច។ ជាតិអាល់កុលដែលមានផ្ទុកនៅក្នុងទឹកខ្ទុរមាត់សម្ងួតមុនទាំងនោះយ៉ាងឆាប់រហ័ស ព្រមទាំងសម្លាប់បាក់តេរីទប់ស្កាត់មិនឱ្យឆ្លងមេរោគផងដែរ។ បើប្រៀបធៀបទៅនឹងទឹកថ្នាំកម្ចាត់មុនដទៃទៀតដាក់លក់តាមទីផ្សារដែលមានផ្ទុកសារធាតុគីមីខ្លាំង នោះទឹកខ្ទុរមាត់ គឺជាផលិតផលប្រសើរបំផុតសម្រាប់សុខភាពស្បែករបស់អ្នក។







# មិត្តតុកាហ្វេ ង៉ែត ឈួន មិនបានមកទៀតទេ!

ដោយ ពិន សំខុន

លោក ង៉ែត ឈួន បានលាចាកនៅថ្ងៃទី ១៦ ខែមេសា ២០២០ កន្លងទៅនេះ ដោយជរាពាធ នឹងនៅពេលដួលនៅផ្ទះរបស់លោក នៅជន្មាយុ៧៥ឆ្នាំ គឺនៅពេលដែលជម្ងឺកូវីដ១៩ កំពុងពេញគម្រោមរាតត្បាតសហរដ្ឋអាមេរិកយ៉ាងដំណំ ។

លោក ឈួន តែងតែមកអង្គុយពិសារកាហ្វេជារៀងរាល់ព្រឹក នៅភោជនីយដ្ឋាន "ភ្នំពេញ"នៅ ផ្លូវ វ៉េសហ្វឺត ក្រុងឡូវែល មិនសូវដែលខកខានទេ ពីព្រោះទីនោះ លោកនឹងបានជួបជុំមិត្តរួមគំនិត រួមការម្នាក់ឈ្មោះ ឬទ្ធី សៅ បានចងចាំថា បង ឈួន បានមកចូលរួមតុកាហ្វេមិនតិចជាង២០ឆ្នាំមកហើយទេ។

ចំណងមិត្តភាពដ៏យូរឆ្នាំនោះ បានធ្វើឱ្យ "ក្រុមតុកាហ្វេភ្នំពេញ" តឹងតែងក្នុងចិត្តអួលដើមក ចំពោះដំណឹងពីការលាចាកលោករបស់រៀមច្បង ដែលតែងតែត្រដរ មកកាន់តុកាហ្វេ បើទោះជាជរាពាធរបស់លោកកាន់តែយាយី ធ្វើឱ្យលំបាកក្នុងការ ចុះឡើងពីផ្ទះ៣ជាន់ នឹងការធ្វើដំណើរមកកាន់តុកាហ្វេក៏ដោយ ។ លោកតែងតែស្ម័គ្រចិត្តជួយដល់ការផ្តួចផ្តើមជួយប្រជាពលរដ្ឋខ្មែរ នឹងជួយដល់គណបក្សសង្គ្រោះជាតិ មិនដែលខកខានឡើយ ។ លោក ង៉ែត ឈួន បានក្លាយជាមិត្តដ៏គួរគោរពស្រឡាញ់ គេបានដណ្តើមគ្នាអូសកៅអីមកអង្គុយជិតគាត់ជារឿយៗគ្មាននរណាម្នាក់ចង់ឱ្យគាត់ចាកចេញទៅជារៀងរហូតយ៉ាងនេះឡើយ ។



លោក ង៉ែត ឈួន

រីតតែមិនចង់ឱ្យចាកចេញទៅទៀត គឺភរិយារបស់គាត់អ្នកស្រី សាន អ៊ូ អាយុប្រហាក់ប្រហែលគ្នា តែនៅមាំទាំជាង, ជាអ្នកដឹកជញ្ជូនគាត់ទៅពេទ្យ ទៅកំសាន្តឯតុកាហ្វេ ថែទាំបុរសដែលជាប្តីសំឡាញ់ តាំងតែពីឆ្នាំ១៩៨៨មក, អ្នកស្រីបានរៀបរាប់ទាំងទឹកភ្នែករលីងរលោងពីការរស់នៅតែម្នាក់ឯងយ៉ាងហេងហាងក្នុងផ្ទះ៤បន្ទប់ ដ៏ស្អាតច្រឡឹង... បង្ហាញពីរូបថតអតីតកាលច្រើនសន្លឹក ពេលខ្លះ ក៏ផ្អែមល្ហែម ពេលខ្លះក៏ល្វីងជូចត់ តែជីវិតដែលគាត់បានផ្តើមតាំងតែពីមកដល់សហរដ្ឋ នាឆ្នាំ១៩៨៤ ទៅរៀបការយកអ្នកស្រី អ៊ូ ពិរដ្ឋតិចសាស់ មក។ អ្នកស្រី អ៊ូ បន្តថា ប្តីគាត់មិនត្រឹមតែជាមនុស្សដែល គេចូលចិត្តតែប៉ុណ្ណោះទេ គាត់ក៏ជាមនុស្សឧស្សាហ៍ធ្វើការណាស់ដែរ, ធ្វើការរហូតនៅហាង "បាស្តូស" ជាអ្នកធ្វើការ Union worker នៅទីនោះ ក៏មានមិត្តគាត់ច្រើនណាស់ដែរ ។



លោក ង៉ែត ឈួន និងអ្នកស្រី សាន អ៊ូ

នៅតុកាហ្វេលោក ង៉ែត ឈួន តែងរៀបរាប់អំពីជំនាញរបស់គាត់ តែម្នាក់ឯង ខាងមុជទឹកជ្រៅ, ក្រុមខ្មែរក្រហម បានបញ្ជាឱ្យគាត់មុជទឹកសមុទ្រនា "កោះតាំង" ។ ទីនោះគាត់ត្រូវតែរកកប៉ាល់អាមេរិក ដែលក្រុមខ្មែរ ក្រហមបានបាញ់លិច កាលពីជំនាន់ លន់ នល់ ហើយក៏មានចាប់បានទាហ៊ានអាមេរិកាំងថែមទៀតផង។ លោក ឈួន បានរកឃើញកប៉ាល់អាមេរិកាំងនោះ, ដោយសារទេព្យកោសល្យខាងមុជទឹកជ្រៅ ហើយបានយូរទៀតផង។ មករស់នៅកោះតាំង តែតាមពិតគាត់ជាអ្នកស្រុកកំពង់ស្ពឺសោះ។

មិត្តភក្តិទាងអស់រួមទាំងសមាជិក សមាជិកា "សមាគមអេសេឡិក" នឹងគណបក្សសង្គ្រោះជាតិ ជាមួយនឹងការគោរពរាប់អានដ៏ជ្រាលជ្រៅ បានចូលចាប់កុសលជួយដល់គ្រួសារលោក ឈួន ជាប្រាក់១៤៤០ដុល្លារ នាឱកាសចុង ក្រោយរបស់លោក នឹងសូមជូនពរ "លោក ង៉ែត ឈួន ឱ្យបានជួបតែសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ" ។



លោក ង៉ែត ឈួន (រូបថតចុងក្រោយឆ្វេងបង្អស់) នៅតុកាហ្វេ



លោក ង៉ែត ឈួន កាលនៅកំលោះ

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេក
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវា ជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រ៉ង ឃេឃេ អ៊ីនស្វូរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business
508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com


# អាមេរិក: អត្រាចំនួនអ្នកគ្មានការងារធ្វើបានកើនឡើងលើសពី ២០% និងបាត់បង់ការងារចំនួន ២៦.៥ លាន

គិតមកត្រឹមពាក់កណ្ដាលខែមេសា មានពលរដ្ឋអាមេរិចជាង ៤.៤ លាននាក់ហើយបានដាក់ពាក្យសុំឧបត្ថម្ភពីកម្មវិធីជំនួយសម្រាប់អ្នកបាត់បង់ការងារ ។ ចំនួននៃការដាក់ពាក្យនេះធ្លាក់ក្រោយដែលមានចំនួនអ្នកអត់ការងារធ្វើ ២៦.៥ លាននាក់ ។ បើយកទូរលេខទាំងពីនេះបូកបញ្ចូលគ្នា យើងនឹងឃើញថាចំនួនអ្នកអត់ការងារធ្វើ គឺច្រើនជាង ៣៣ លាននាក់ រីអត្រាគ្មានការងារពិត




ចុះបើប្រៀបធៀបពីដើមខែមេសា ដែលមានចំនួនរហូតដល់ ៥.២ លាននាក់ ។ ប៉ុន្តែ ៥ សប្ដាហ៍ជាប់ៗគ្នាហើយដែលចំនួនអ្នកដាក់ពាក្យលើសពី ៣លាននាក់ នេះបើយោងតាមក្រសួងការងាររបស់អាមេរិច ។

កាលពីវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៨ មានជនជាតិអាមេរិកាំងអត់ការងារធ្វើចំនួន១៥.៣លាននាក់ ដែលជាកម្រិតខ្ពស់បំផុតនៃការអត់ការងារធ្វើ ។ ប៉ុន្តែក្នុងរយៈពេល៥សប្ដាហ៍កន្លងមកនេះ មានចំនួនអ្នកអត់ការងារ ដែលដាក់ពាក្យសុំជំនួយមានរហូតដល់ ២៦.៥ លាននាក់ ។

ចំនួនអ្នកគ្មានការងារប្រចាំសប្ដាហ៍ ២០២០

យោងតាមការិយាល័យស្ថិតិការងារសហរដ្ឋអាមេរិកបានឱ្យដឹងថាកាលពីពាក់កណ្ដាលខែមិនា គេឃើញមានចំនួនអ្នកអត់ការងារធ្វើមានរហូតដល់ ៧.១ លាននាក់ មុនរយៈពេល ៥ សប្ដាហ៍ចុងប្រាកដមានចំនួន ២០.៦% ដែលនេះជាកំរិតខ្ពស់បំផុតចាប់តាំងពីឆ្នាំ ១៩៣៤ ។

យើងសង្កេតឃើញថា នៅរដ្ឋមួយចំនួនដូចជាតិចសាស មានអត្រាអ្នកគ្មានការងារកាន់តែខ្ពស់ ហើយរដ្ឋបានចំណាយអស់ថវិការបស់ខ្លួនដែលបានរក្សាទុកសម្រាប់ជួយឧបត្ថម្ភដល់ពលរដ្ឋដែលបានដាក់ពាក្យសុំជំនួយ ។ ដើម្បីបន្តការឧបត្ថម្ភដល់អ្នកគ្មានការងារធ្វើរដ្ឋទាំងនេះត្រូវបង្ខំចិត្តខ្ចីលុយពីរដ្ឋាភិបាលសហព័ន្ធ ។

សម្រាប់អ្នកបាត់បង់ការងារហើយមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋនឹងទទួលបានប្រាក់បន្ថែមចំនួន ៦០០ ដុល្លាររាល់មួយសប្ដាហ៍ម្ដងរហូតដល់ថ្ងៃទី៣១ ខែកក្កដា ។ ថវិកាបន្ថែមនេះ គឺបានមកពីកញ្ចប់ថវិកាសង្គ្រោះបន្ទាន់ ២.២% ទ្រីលានដុល្លារ ។

ការិយាល័យ មេធាវី
ចំមាស ស្ពាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

## សេចក្ដីជូនដំណឹងស្ដីពី

**ការរៀបចំកិច្ចប្រជុំជាសាធារណៈ និងឱកាសក្នុងការផ្ដល់មតិយោបល់: ពង្រៀងគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន FFY ឆ្នាំ ២០២១ -២០២៥ របស់អង្គភាពរៀបចំក្រុង ន័សធន ម៉ីឌូលសិច**

អង្គភាពរៀបចំក្រុង ន័សធន ម៉ីឌូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO បានប្រកាសផ្សព្វផ្សាយដើម្បីឱ្យសាធារណៈជនធ្វើការផ្ដល់ជាមតិយោបាលទៅលើពង្រៀងគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០២១-២០២៥ ។ សំណើរពង្រៀងនេះ គឺជាការរៀបចំកម្មវិធី និងឯកសារក្នុងការគ្រប់គ្រង់ ដែលមានរួមបញ្ចូលទាំងគម្រោងដឹកជញ្ជូនដែលទទួលបានហិរញ្ញវត្ថុពីសហព័ន្ធសម្រាប់រយ:ពេល៥ឆ្នាំ ។ លោកអ្នកអាចទទួលបានច្បាប់ចម្លងនៃពង្រៀងគម្រោងនេះតាមរយៈនៅវ៉ិបសាយ www.nmcog.org ។

មានកិច្ចប្រជុំពីរដែលបានគ្រោងរៀបចំឡើងកាលពីពេលថ្មីៗនេះ ។ ទីមួយ កិច្ចប្រជុំជាសាធារណៈដើម្បីទទួលយកនូវមតិយោបល់ពីសាធារណៈជនទៅលើពង្រៀង TIP ដែលនឹងប្រព្រឹត្តទៅនៅម៉ោង ៥:៣០ល្ងាច ទី ១២ ខែឧសភា ។ លោកអ្នកក៏អាចផ្ដល់ជាមតិយោបល់តាមរយៈទូរស័ព្ទដោយខលទៅកាន់លេខ (978) 454-8021, ext ។ ១២១ រឺតាមរយៈអ៊ីម៉េល jhoward@nmcog.org រឺផ្ញើជាសំបុត្រមកកាន់ NMCOG តាមអាស័យដ្ឋាន 40 Church Street, Suite 200, Lowell MA 01852 ។ រយៈពេលនៃការទទួលនូវមតិយោបល់ចំពោះគម្រោង TIP នេះ នឹងបញ្ចប់នៅថ្ងៃទី២២ ខែឧសភា ។ កិច្ចប្រជុំទីពីនឹងរៀបចំនៅ NMMPO ដែលគ្រោងនឹងប្រព្រឹត្តទៅនៅម៉ោង ២:០០រសៀល ថ្ងៃទី២៧ ខែឧសភា នៅពេលដែរគម្រោង TIP FFY ឆ្នាំ ២០២១-២០២៥ នឹងត្រូវពិចារណាក្នុងការធ្វើវិសោធនកម្ម ។ ដំណើរការនៃការរៀបចំប្រជុំចូលរួមជាសាធាណៈរបស់ NMMPO គឺវាសមស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើន ។

**កំណត់ចំណាំ:** ដោយសារតែរដ្ឋស្ថិតក្នុងភាពអាសន្ន កិច្ចប្រជុំទាំងអស់នេះ នឹងត្រូវរៀបចំឡើងស្ទើរតែទាំងអស់តាមរយៈកម្មវិធីខលវីដេអូ Zoom ។ ព័ត៌មានពីការចូលរួមក្នុងកិច្ចប្រជុំនេះ នឹងត្រូវដាក់ផ្សព្វផ្សាយតាមវេបសាយ www.nmcog.org ។ លោកអ្នកក៏អាចទទួលបានព័ត៌មានពីការចូលរួមក្នុងកិច្ចប្រជុំនេះដោយទូរស័ព្ទទៅកាន់លេខ ៩៧៨-៤៥៤-៨០២១, ខេត ។ ១២១. អង្គភាព NMMPO ផ្ដល់នូវការស្នាក់នៅដ៏សមរម្យ និង, រឺជំនួយផ្នែកភាសា ដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ (មានដូចជាអ្នកបកប្រែតាមការធ្វើសញ្ញា និងភាសាផ្សេងទៀតក្រៅភាសាអង់គ្លេស, បកប្រែភាសាដោយមើល រឺស្ដាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៏បកប្រែជាសម្លេងសម្រាប់អ្នកគរ ថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀត) តាមដែលមាន ។ សម្រាប់ជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ខេត 121 រឺអ៊ីម៉េលទៅកាន់ jhoward@nmcog.org ។ រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ ។

## NOTICE OF PUBLIC MEETINGS AND COMMENT OPPORTUNITY: Draft NMMPO FFY 2021-2025 Transportation Improvement Program

The Northern Middlesex Metropolitan Planning Organization (NMMPO) has released for public comment the draft FFY 2021-2025 Transportation Improvement Program (TIP). The TIP is a programming and management document containing all federally funded transportation projects planned over the next 5 years. Copies of the draft document can be found at www.nmcog.org.

There are two virtual public meetings currently scheduled. First, a public meeting to receive comments on the draft TIP will be held on May 12, 5:30 PM. You may also submit comments by phone at (978) 454-8021, ext. 121, or by email: jhoward@nmcog.org or by mailing to NMCOG, 40 Church Street, Suite 200, Lowell MA 01852. The public comment period for the TIP ends May 22. The second is a meeting of the NMMPO scheduled for May 27, 2:00 PM when the Draft FFY 2021-2025 TIP will be considered for endorsement. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

**Notice:** Due to the ongoing state of emergency, these meetings will be held virtually via the Zoom platform. Information about accessing these meetings will be posted at www.nmcog.org. You can also get information on access to the meeting by calling 978-454-8021, ext. 121. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext. 121 or at jhoward@nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including sign language, CART or language translation or interpretation.


កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ
AccuCare
Home Care Agency
Group Adults Foster Care Program
បើលោកអ្នកមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅ
ជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។
At no Cost to you
សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិក
ខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide
បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell,
Lynn, Revere, Boston និងតំបន់ជុំវិញ
ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
• រស់នៅផ្ទះរដ្ឋ
• អាយុ ២២ ឆ្នាំឡើងទៅ
• មានសំបុត្រពេទ្យស្តង់ដា
ផលប្រយោជន៍ទទួលបាន :
• ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
• ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
• ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
• វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
• សមាជិកអាចទាក់ទងមក២៤ម៉ោង
To be eligibled for GAFC you must:
• live in subsidized or public housing
• age 22 years and older
• eligible for Masshealth Standard
Benefits you will get:
• personal care service in your home,
• Medication Managemant
• an individual care plan developed by a registered nurse and case manager
• ongoing monitoring of needs
• 24-hour access to services
ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ "ខេជីអេ"

## អវសាន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

ក៏សុំនិយាយជាមួយនឹង ពិន សំខុន ពេលនោះសំខុនក៏តបថា "លោក យិនទៀង ថ្វីត្បិតតែមានដំណែងខ្ពស់ក្នុងរដ្ឋ តែមិននៅក្នុង KJA ទេ ដូច្នេះមិនអាចធ្វើសំណើរនេះបានទេ", ពេលនោះ លោក យិនទៀង ក៏ចាប់ធ្វើការគម្រាមថា បង សំខុន ឯងមានដែលឃើញរូបថតដែលគេផ្សាយពីចលនាតស៊ូថ្មីៗនេះទេ? ពិន សំខុន គិតមួយសន្ទុះ ក៏តបថា ខ្ញុំបានឃើញហើយ តើរូបទាំងនោះ ជាគំនិតលោក យិនទៀង ឯងឬ ? លោក យិនទៀង ឆ្លើយថា មែនហើយ! សំខុន តបភ្លាមថា "លោកស្គាល់ខ្ញុំ តិចពេកហើយ ខ្ញុំមិនដែលខ្លាចការគម្រាមណាមួយទេ សូម្បីតែមកពីលោក ហ៊ុន សែន ជាចៅហ្វាយលោកក៏ដោយ!!" និយាយបានតែត្រឹមនេះ លីហុក ក៏កញ្ឆក់ទូរស័ព្ទពីដៃ សំខុន ហើយ និយាយបែបខ្សឹបៗប្រាប់សំខុនថា សូមឯងទុកឱ្យគ្នាដោះស្រាយវិញ ពីព្រោះគេជាចៅហ្វាយគ្នាផង... ថារួចហើយ ក៏ងាកទៅបន្តជាមួយលោក ឱម យិនទៀង ថា សូមទុកឱ្យខ្ញុំនិយាយជាមួយ សំខុន ចុះ រួចចាំខ្ញុំទូរស័ព្ទទៅវិញ។ មានរូបថត ជាមួយចលនាតស៊ូនៅជាយដែនបានន័យថា យិនទៀង អាចនឹងចាប់ខ្លួនសំខុន ហើយចោទប្រកាន់ថា ជាអ្នកចូលដៃនឹងចលនាក្រៅច្បាប់ CFF...។ ដាក់ទូស័ព្ទពីលោក យិនទៀង ហើយ លីហុក ក៏និយាយជាមួយ សំខុន ថា លោក យិនទៀង ជាចៅហ្វាយគ្នាខ្ញុំអាចនឹងមានបញ្ហានៅកន្លែងធ្វើការ តើគិតយ៉ាងម៉េចទៅ? សំខុន ក៏ផ្តល់លទ្ធភាពទៅឡិហុក ថា "ឯងជាអ្នកសម្រេច ចុះក្រោមការទទួលខុសត្រូវខ្លួនឯង ពីព្រោះ ឥឡូវ លីហុក ឯងក៏ជាសហប្រធានទៅហើយដែរ ។

សូ ណារ៉ូ ក៏បានត្រឡប់មកចូលសមាគមក្នុងឋានៈជាអគ្គលេខាវិញ ប្រកបដោយចិត្តអស់ឯក ពីព្រោះទាំងបុគ្គលិកទាំងសមាជិកមួយភាគធំ គេបានមើលឃើញថា ណារ៉ូ ជាអ្នកដែលបានធ្វើឱ្យ KJA អាប់ឱនកិត្តិយស ។


លោក ឱម យិនទៀត


ពិន សំខុន


ពាត លីហុក


សូណារ៉ូ

ការដណ្តើមអំណាចរបស់លោក ហ៊ុន សែន នៅតែបន្តរឹតតែតឹងតែងប្រកបដោយឈាម, កងទ័ពក្រោមបញ្ជាហ៊ុនសិុនប៉ិច ក៏ត្រូវកំចាត់ម្តងមួយៗនៅគ្រប់កន្លែងលើផ្ទៃប្រទេស ។ ទ្រង់រណប្ញទ្ធិជានាយករដ្ឋមន្ត្រីទី១ បានបញ្ជាទាញកាំភ្លើងយន្តពីបរទេសសម្រាប់បំពាក់ឱ្យអង្គរក្សរបស់ព្រះអង្គ ក៏បានត្រូវលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ បញ្ជាឱ្យចាប់រឹបអូសនៅអាកាសយានស្ថានពោធិចិនតុង ធ្វើឱ្យទំនាក់ទំនងរឹតតែតឹងក្នុងការគ្រប់គ្រងនយោបាយប្រទេសនៃមេដឹកនាំខ្មែរទាំង២រូប ។

ព្រឹត្តការទំនាស់នយោបាយប្រទូសរ៉ាយក្នុងស្រុកបានជាចំណើព័តិមានយ៉ាងឈ្ងុយឆ្ងាញ់។ អ្នកកាសែតទាំងខ្មែរទាំងបរទេសបញ្ជូនភ្នាក់ងារប្រសេចប្រសាចទៅគ្រប់ក្រសួងគ្រប់ទីស្នាក់ការគណបក្ស ។ លោក សម រង្ស៊ី ប្រធានគណបក្សជាតិខ្មែរ បានឱកាសបង្កើនសកម្មភាពជាមួយសហជីពកម្មករជាមួយប្រជាពលរដ្ឋដែលចង់ផ្លាស់ប្តូរសង្គមធ្វើបាតុកម្មស្ទើររាល់ថ្ងៃ រីឯកាសែតរបស់ក្រុមលោក សម រង្ស៊ី ប្រមាណជា១០អង្គភាព, វិទ្យុនឹងកាសែតគាំទ្រគណបក្សហ៊ុនសុិនប៉ិច ៤,៥ អង្គភាព ក៏បញ្ចេញអត្ថបទវាយប្រហារ

តទៅលេខក្រោយ






# Steps to help prevent the spread of COVID-19 if you are sick

**FOLLOW THE STEPS BELOW:** If you are sick with COVID-19 or think you might have it, follow the steps below to help protect other people in your home and community.

## Stay home except to get medical care



- **Stay home:** People who are mildly ill with COVID-19 are able to recover at home. Do not leave, except to get medical care. Do not visit public areas.
- **Stay in touch with your doctor.** Call before you get medical care. Be sure to get care if you feel worse or you think it is an emergency.
- **Avoid public transportation:** Avoid using public transportation, ride-sharing, or taxis.

## Separate yourself from other people in your home, this is known as home isolation



- **Stay away from others:** As much as possible, you should stay in a specific "sick room" and away from other people in your home. Use a separate bathroom, if available.
- **Limit contact with pets & animals:** You should restrict contact with pets and other animals, just like you would around other people.
  - Although there have not been reports of pets or other animals becoming sick with COVID-19, it is still recommended that people with the virus limit contact with animals until more information is known.
  - When possible, have another member of your household care for your animals while you are sick with COVID-19. If you must care for your pet or be around animals while you are sick, wash your hands before and after you interact with them. See COVID-19 and Animals for more information.

## Call ahead before visiting your doctor



- **Call ahead:** If you have a medical appointment, call your doctor's office or emergency department, and tell them you have or may have COVID-19. This will help the office protect themselves and other patients.

## Wear a facemask if you are sick



- **If you are sick:** You should wear a facemask when you are around other people and before you enter a healthcare provider's office.
- **If you are caring for others:** If the person who is sick is not able to wear a facemask (for example, because it causes trouble breathing), then people who live in the home should stay in a different room. When caregivers enter the room of the sick person, they should wear a facemask. Visitors, other than caregivers, are not recommended.

## Cover your coughs and sneezes



- **Cover:** Cover your mouth and nose with a tissue when you cough or sneeze.
- **Dispose:** Throw used tissues in a lined trash can.
- **Wash hands:** Immediately wash your hands with soap and water for at least 20 seconds. If soap and water are not available, clean your hands with an alcohol-based hand sanitizer that contains at least 60% alcohol.

## Clean your hands often



- **Wash hands:** Wash your hands often with soap and water for at least 20 seconds. This is especially important after blowing your nose, coughing, or sneezing; going to the bathroom; and before eating or preparing food.
- **Hand sanitizer:** If soap and water are not available, use an alcohol-based hand sanitizer with at least 60% alcohol, covering all surfaces of your hands and rubbing them together until they feel dry.
- **Soap and water:** Soap and water are the best option, especially if hands are visibly dirty.
- **Avoid touching:** Avoid touching your eyes, nose, and mouth with unwashed hands.

## Avoid sharing personal household items



- **Do not share:** Do not share dishes, drinking glasses, cups, eating utensils, towels, or bedding with other people in your home.

**cdc.gov/COVID19**

CS 316129-A 03/20/2020

- **Wash thoroughly after use:** After using these items, wash them thoroughly with soap and water or put in the dishwasher.

## Clean all "high-touch" surfaces everyday



Clean high-touch surfaces in your isolation area ("sick room" and bathroom) every day; let a caregiver clean and disinfect high-touch surfaces in other areas of the home.

- **Clean and disinfect:** Routinely clean high-touch surfaces in your "sick room" and bathroom. Let someone else clean and disinfect surfaces in common areas, but not your bedroom and bathroom.
  - If a caregiver or other person needs to clean and disinfect a sick person's bedroom or bathroom, they should do so on an as-needed basis. The caregiver/other person should wear a mask and wait as long as possible after the sick person has used the bathroom.
- High-touch surfaces include phones, remote controls, counters, tabletops, doorknobs, bathroom fixtures, toilets, keyboards, tablets, and bedside tables.
- **Clean and disinfect areas that may have blood, stool, or body fluids on them.**
- **Household cleaners and disinfectants:** Clean the area or item with soap and water or another detergent if it is dirty. Then, use a household disinfectant.
  - Be sure to follow the instructions on the label to ensure safe and effective use of the product. Many products recommend keeping the surface wet for several minutes to ensure germs are killed. Many also recommend precautions such as wearing gloves and making sure you have good ventilation during use of the product.
  - Most EPA-registered household disinfectants should be effective. A full list of disinfectants can be found hereexternal icon.

## Monitor your symptoms



- **Seek medical attention, but call first:** Seek medical care right away if your illness is worsening (for example, if you have difficulty breathing).
  - **Call your doctor before going in:** Before going to the doctor's office or emergency room, call ahead and tell them your symptoms. They will tell you what to do.
- **Wear a facemask:** If possible, put on a facemask before you enter the building. If you can't put on a facemask, try to keep a safe distance from other people (at least 6 feet away). This will help protect the people in the office or waiting room.
- **Follow care instructions from your healthcare provider and local health department:** Your local health authorities will give instructions on checking your symptoms and reporting information.

If you develop **emergency warning signs** for COVID-19 get **medical attention immediately.**

Emergency warning signs include*:

- Difficulty breathing or shortness of breath
- Persistent pain or pressure in the chest
- New confusion or inability to arouse
- Bluish lips or face

*This list is not all inclusive. Please consult your medical provider for any other symptoms that are severe or concerning.

**Call 911 if you have a medical emergency:** If you have a medical emergency and need to call 911, notify the operator that you have or think you might have, COVID-19. If possible, put on a facemask before medical help arrives.

## How to discontinue home isolation



- People **with COVID-19 who have stayed home (home isolated)** can stop home isolation under the following conditions:
  - ***If you will not have a test*** to determine if you are still contagious, you can leave home after these three things have happened:
    - You have had no fever for at least 72 hours (that is three full days of no fever without the use medicine that reduces fevers)
      AND
    - other symptoms have improved (for example, when your cough or shortness of breath have improved)
      AND
    - at least 7 days have passed since your symptoms first appeared
  - ***If you will be tested*** to determine if you are still contagious, you can leave home after these three things have happened:
    - You no longer have a fever (without the use medicine that reduces fevers)
      AND
    - other symptoms have improved (for example, when your cough or shortness of breath have improved)
      AND
    - you received two negative tests in a row, 24 hours apart. Your doctor will follow CDC guidelines.

**In all cases, follow the guidance of your healthcare provider and local health department.** The decision to stop home isolation should be made in consultation with your healthcare provider and state and local health departments. Local decisions depend on local circumstances.

More information is available here.

Additional information for healthcare providers: Interim Healthcare Infection Prevention and Control Recommendations for Persons Under Investigation for 2019 Novel Coronavirus.